ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០១៩......សហវ.......

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតគណៈកម្មការអន្តរក្រសួងចំពោះកិច្ច ដើម្បីបន្តបំពេញនីតិវិធី លើការរំសាយផ្លាក់ខារកម្ពុជានាវាចរ "កាំសាប"

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី ២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី ១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញអនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី៥ ខែ កុម្ភៈ ឆ្នាំ២០១៩ ស្តីពីការរំសាយសហគ្រាសសាធារណៈភ្នាក់ងារកម្ពុជានាវាចរ ហៅថា “កាំសាប”
- បានឃើញលិខិតលេខ ៣១២ សក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងតាមតម្រូវការចាំបាច់របស់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងចំពោះកិច្ច ដើម្បីបន្តបំពេញនីតិវិធី លើការរំសាយភ្នាក់ងារកម្ពុជានាវាចរ (**កាំសាប**) តទៅហៅថា “**គណៈកម្មការចំពោះកិច្ច**” ដូចមានសមាសភាពខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ជូ ទិជិត្ត** | រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. ឯកឧត្តម **ស្ងួន ហោន** | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣. ឯកឧត្តម **នេត មុន្នី** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (អ.ទ.ច) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤. លោក **ម៉ែន ទុត្តា** | ប្រធាននាយកដ្ឋានសហគ្រាសសាធារណៈ នៃ អ.ទ.ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. លោក **ជា ទណ្ណារ័ត្ន** | ប្រធាននាយកដ្ឋានចំណូលថវិកា នៃអគ្គនាយកដ្ឋានរតនាគារជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦. លោក **អ៊ុំ សុផល** | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៧. លោក **ម៉ាន ម៉ុនណារិត** | ប្រធាននាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន នៃ អ.ទ.ច ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក។ |

**ប្រការ ២.-**

គណៈកម្មការចំពោះកិច្ច មានភារកិច្ចដូចខាងក្រោម÷

- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងរៀបចំរបាយការណ៍បិទបញ្ជីទូទាត់ ពាក់ព័ន្ធនឹងការបើកផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយ ដែលរាជរដ្ឋាភិបាលបានកំណត់ជូននិយោជក និងនិយោជិតរបស់ **កាំសាប**
- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបិទបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ **កាំសាប** សម្រាប់ឆ្នាំ២០១៨ និងសម្រាប់ការិយបរិច្ឆេទចុងក្រោយនៃឆ្នាំ២០១៩

- ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាព ចំពោះតម្រូវការប្រើប្រាស់ និងការចាត់ចែងបន្ត លើទ្រព្យសម្បត្តិរបស់**កាំសាប** ដែលក្នុងនោះមាន អចលនវត្ថុ, គ្រឿងចក្រ, យានយន្ត, សង្ហារឹម, សម្ភារៈ និងបរិក្ខារការិយាល័យ, រតនៈវត្ថុ និងភាគហ៊ុន
- ត្រួតពិនិត្យ ផ្ទៀងផ្ទាត់ និងបិទបញ្ជីគណនេយ្យ ដែលក្នុងនោះមាន ចំណូល, ចំណាយ, ចំណេញ, កាតព្វកិច្ចបង់ចំណូលថវិការដ្ឋ, ការទូទាត់ និងជម្រះបំណុល និងកាតព្វកិច្ចហិរញ្ញវត្ថុដទៃទៀត
- រៀបចំរបាយការណ៍បូកសរុបលទ្ធផលការងារខាងលើ ដែលបានប្រគល់ភារកិច្ចជូនគណៈកម្មការចំពោះកិច្ច ដើម្បីគោរពសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចំពោះការផ្ទេរទ្រព្យសម្បត្តិ, ការបើកផ្តល់ប្រាក់ឧបត្ថម្ភគោលនយោបាយ និងការចាត់ចែងពិនិត្យបិទបញ្ជីគណនេយ្យ រួមទាំងបំណុលត្រូវទារ និងបំណុលត្រូវសង និងកាតព្វកិច្ចហិរញ្ញវត្ថុដទៃទៀត ព្រមទាំងសំណូមពរជាយថាហេតុដទៃទៀតរបស់គណៈកម្មការចំពោះកិច្ច
- អនុវត្តភារកិច្ចផ្សេងទៀត ជាយថាហេតុ ពាក់ព័ន្ធនឹងការរំសាយ **កាំសាប** តាមការកំណត់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន។

**ប្រការ ៣.-**

គណៈកម្មការចំពោះកិច្ច មានក្រុមការងារបច្ចេកទេស ដែលមានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១. ឯកឧត្តម **នេត មុន្នី** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធ (អ.ទ.ច) ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២. លោក **វណ្ណា សំណាង** | អនុប្រធាននាយកដ្ឋានសហគ្រាសសាធារណៈ នៃ អ.ទ.ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៣. លោក **ជេត វាសនា** | អនុប្រធាននាយកដ្ឋានសហគ្រាសសាធារណៈ នៃ អ.ទ.ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤. លោក **ណាំ ស៊ីនិត** | អនុប្រធាននាយកដ្ឋានចំណូលពីទ្រព្យសម្បត្តិរដ្ឋ នៃអ.ទ.ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥. លោកស្រី **គីម បទុមគន្ធា** | ប្រធានការិយាល័យគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងសហគ្រាសសាធារណៈនៃនាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៦. លោក **កេត ម៉ារ៉ូ** | ប្រធានការិយាល័យគណនេយ្យ-ហិរញ្ញវត្ថុនៃភ្នាក់ងារកម្ពុជានាវាចរ | សមាជិក |
| ៧. លោកស្រី **ហែម ច័ន្ទស្រីសម្បត្តិ** | អនុប្រធានការិយាល័យគណនេយ្យ-ហិរញ្ញវត្ថុនៃភ្នាក់ងារកម្ពុជានាវាចរ | សមាជិក |
| ៨. លោក **ផាន់ មករា** | អនុប្រធានការិយាល័យនៃនាយកដ្ឋានសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនៃ អ.ទ.ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៩. លោកស្រី **ឃី ស្រីស្រស់** | មន្ត្រី នៃអ.ទ.ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក។ |

**ប្រការ ៤.-**

ក្រុមការងារបច្ចេកទេស នៃគណៈកម្មការចំពោះកិច្ចនេះ មានភារកិច្ចដូចខាងក្រោម÷

- បំពេញតួនាទីជាសេនាធិការឱ្យគណៈកម្មការចំពោះកិច្ច លើកិច្ចការងារ ដែលមានចែងក្នុងប្រការ ២
- ចុះប្រមូលព័ត៌មានពាក់ព័ន្ធនឹងទ្រព្យសម្បត្តិ និយោជក និងនិយោជិតរបស់ **កាំសាប** តាមការចង្អុលបង្ហាញរបស់គណៈកម្មការចំពោះកិច្ច
- ផ្តល់យោបល់ និងរៀបចំរបាយការណ៍ស្តីពីលទ្ធផលការងារ ជូនគណៈកម្មការចំពោះកិច្ច
- រៀបចំឯកសារ និងកំណត់ហេតុកិច្ចប្រជុំ នៃគណៈកម្មការចំពោះកិច្ច
- បំពេញភារកិច្ចផ្សេងទៀតតាម ការកំណត់របស់គណៈកម្មការចំពោះកិច្ច។

**ប្រការ ៥.-**

គណៈកម្មការចំពោះកិច្ច ត្រូវដំណើរការកិច្ចប្រជុំតាមការអញ្ជើញ និងក្រោមការដឹកនាំរបស់ប្រធានគណៈកម្មការ។ ប្រធានគណៈកម្មការ អាចប្រគល់សិទ្ធិជូនអនុប្រធានគណៈកម្មការ ដើម្បីដឹកនាំកិច្ចប្រជុំក្នុងករណីប្រធានអវត្តមាន។

គណៈកម្មការចំពោះកិច្ច មានសិទ្ធិអញ្ជើញនិយោជក និងនិយោជិតរបស់ **កាំសាប** និងមន្ត្រីជំនាញពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការ និងដឹកជញ្ជូន ចូលរួមក្នុងការងារនេះតាមការចាំបាច់។

**ប្រការ ៦.-**

គណៈកម្មការចំពោះកិច្ចនេះ ព្រមទាំងក្រុមការងារបច្ចេកទេស ត្រូវបញ្ចប់បេសកកម្មរបស់ខ្លួន នៅពេលដែល **កាំសាប** ត្រូវបានបំពេញនីតិវិធីរំលាយ ចប់ជាស្ថាពរ។

**ប្រការ ៧.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការ និងប្រធានអង្គភាពនានា ដែលស្ថិតក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងសាមីខ្លួន ដូចមានចែងក្នុងប្រការ ១ និងប្រការ ៣ ត្រូវទទួលភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃពុធ ២កើត ខែ មាឃ ឆ្នាំ ច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០១៩

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ